**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្ត**

**កំពត**

# ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូង ខេត្តកំពត

សំណុំរឿងរដ្ឋប្បវេណីលេខ:១១
ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០
សាលក្រមរដ្ឋប្បវេណីលេខ:៥១ (ខ)
ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០

បានធ្វើនីតិវិធីទាញហេតុផលផ្ទាល់មាត់ នៅសាលសវនាការនៃសាលាដំបូងខេត្តកំពត។
កាលបរិច្ឆេទធ្វើ និងបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ។

**ចៅក្រមជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលាដំបូង ខេត្តកំពត

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូង ខេត្តកំពត

-ដើមចោទឈ្មោះ [redacted] ស្មាអេល ភេទប្រុស អាយុ២៩ឆ្នាំ ទីលំនៅបច្ចុប្បន្ន [redacted] ។

ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ

-ចុងចម្លើយឈ្មោះ [redacted] សើណាស់ ភេទស្រី អាយុ២៥ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅ [redacted] ។

**១.ខ្លឹមសារនៃការទាមទាររបស់ភាគី:**

+ដើមចោទ

.សុំអោយតុលាការចេញសាលក្រម:

ក.សុំឈប់រស់នៅជាអនីតិសង្វាសពីចុងចម្លើយឈ្មោះ [redacted] សើណាស់

**២.អង្គហេតុនិងចំណុចវិវាទ**

-ដើមចោទ:

តាមពាក្យបណ្តឹងចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ របស់ដើមចោទឈ្មោះ [redacted] ស្មាអេល បានអះអាងថា:ខ្ញុំបាទបានរៀបការតាមប្រពៃណីជាមួយចុងចម្លើយឈ្មោះ [redacted] សើណាស់ អស់រយ:ពេលជាង៥ខែមកហើយ តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់នោះទេ ហើយការរស់នៅជាមួយគ្នាតែងតែមានភាពមិនចុះសម្រុងនឹងគ្នា តែងតែឈ្លោះប្រកែកគ្នា ទើបធ្វើអោយខ្ញុំបាទអស់មនោសញ្ចេតនាក្នុងការរស់នៅជាមួយគ្នាតទៅមុខទៀតបាន ។ នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ ខ្ញុំបាទបានដាក់ពាក្យបណ្តឹងនៅចៅសង្កាត់ត្រើយកោះ ចៅសង្កាត់ត្រើយកោះបានកោះហៅទៅសម្របសម្រួលពេលនោះខ្ញុំទាំងពីរនាក់បានព្រមព្រៀងគ្នា ឈប់រស់នៅជាអនីតិសង្វាសដោយប្រគល់សិទ្ធិឲ្យឈ្មោះ [redacted] សើ

Scanned with CamScanner

ណាស់ មានអំណាចលើកូន ចំណែកអាហារកិច្ចភាគីឈ្មោះ [redacted] សើណាស់ មិនអោយខ្ញុំទទួលខុសត្រូវ និងទ្រព្យសម្បត្តិរួមបានព្រមព្រៀងគ្នាចែករួចរាល់ហើយ ។

## នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិអោយដើមចោទបានថ្លែងការណ៍ៈខ្លួនស្នើសុំចេញតុលាការចេញសាលក្រមសម្រេចតាមការទាមទាររបស់កូនក្តីខ្លួនដោយសម្រេចអោយដើមចោទឈប់រស់នៅជាអនិតិសង្វាសពីចុងចម្លើយ មូលហេតុដែលខ្លួនស្នើសុំព្រោះដោយសារកូនក្តីរបស់ខ្លួនបានរៀបការជាមួយចុងចម្លើយតែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ទេ ហើយក្នុងការរស់នៅជាមួយគ្នាកូនក្តីរបស់ខ្លួននិងចុងចម្លើយមិនបានចុះសម្រុងនឹងគ្នាទេ ហើយកូនក្តីខ្លួនជាមួយនឹងចុងចម្លើយក៏បានព្រមព្រៀងគ្នាលែងលះនៅសាលាសង្កាត់ត្រើយកោះរួចរាល់ហើយ ចំពោះអាហារកិច្ចចិញ្ចឹមកូនខ្លួនទុកអោយកូនក្តីខ្លួនជាអ្នកសម្រេច ។

ដើមចោទឈ្មោះ [redacted] ស្នាអេល បានអះអាងថាៈពេលដោះស្រាយគ្នារឿងលែងលះនៅសាលាសង្កាត់ចុងចម្លើយមិនអោយខ្លួនទទួលខុសត្រូវលើអាហារកិច្ចចិញ្ចឹមកូនទេ ហើយកូនក៏មិនអោយខ្លួនទទួលស្គាល់ដែរ ខ្លួនរៀបការជាមួយចុងចម្លើយហើយរស់នៅជាមួយចុងចម្លើយបានតែចំនួន២០សប្តាហ៍ តែពេលដែលខ្លួននាំចុងចម្លើយទៅមើលអេកូពិនិត្យផ្ទៃពោះគឺកូនមានអាយុ២៥សប្តាហ៍០២ថ្ងៃ ខ្លួនបានសួរដេញដោលចុងចម្លើយ ហើយចុងចម្លើយក៏បានថាមិនមែនជាកូនរបស់ខ្លួនមែន ។

ចុងចម្លើយឈ្មោះ [redacted] សើណាស់ អះអាងតបថាៈពេលដោះស្រាយនោះគឺខ្លួនថាមិនយកមែនតែពេលនោះខ្លួនសុំទាមទារអាហារកិច្ចចិញ្ចឹមកូនផ្តាច់ចំនួន៣.០០០ ដុល្លាអាមេរិក ចំពោះក្រដាសពិនិត្យអេកូនោះខ្លួនមិនចាំថ្ងៃទេហើយខ្លួនបានចោលហើយ ពេលរស់នៅជាមួយគ្នាដើមចោទថាកូននោះមិនមែនជាកូនរបស់គាត់ទេ ហើយពេលនោះខ្លួនបាននិយាយថាមុនពេលខ្លួនរៀបការជាមួយដើមចោទខ្លួនខឹងឪពុកម្តាយហើយក៏បានផឹកស្រាស្រវឹងហើយមានគេចាប់ខ្លួន ។

លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិអោយដើមចោទបានធ្វើសេចក្តីសន្និដ្ឋានថាៈខ្លួននៅតែស្នើសុំអោយតុលាការចេញសាលក្រមសម្រេចតាមការទាមទាររបស់កូនក្តីខ្លួនដដែល ព្រោះអំឡុងពេលរស់នៅជាប្តីប្រពន្ធកូនក្តីខ្លួននិងចុងចម្លើយគឺរស់នៅមិនបានចុះសម្រុងនឹងគ្នានោះទេ ហើយចំពោះរឿងកូនកូនក្តីរបស់ខ្លួនក៏មានការសង្ស័យថាមិនមែនជាកូនរបស់កូនក្តីដែរ ព្រោះកូនក្តីខ្លួនចាប់តាំងពីពេលដែលបានរៀបការជាមួយចុងចម្លើយមកគឺរស់នៅជាមួយគ្នាតែចំនួន២០សប្តាហ៍ប៉ុណ្ណោះ តែពេលដែលកូនក្តីរបស់ខ្លួនជូនចុងចម្លើយទៅពិនិត្យអេកូនដើម្បីមើលផ្ទៃពោះ គឺឃើញថាកូនមានអាយុចំនួន២៥សប្តាហ៍០២ថ្ងៃ ហើយចំពោះអាហារកិច្ចចិញ្ចឹមកូនដែលចុងចម្លើយសុំទាមទារអោយកូនក្តីខ្លួនបង់ផ្តាច់ចំនួន៣.០០០ ដុល្លាអាមេរិក កូនក្តីខ្លួនសុំបដិសេធចោល ។

+ចំណុចវិវាទ ៈចុងចម្លើយសុំទាមទារអាហារកិច្ចចិញ្ចឹមកូនផ្តាច់ចំនួន ៣.០០០ដុល្លាអាមេរិក តែដើមចោទមិនឯកភាព

+ចំណុចគ្មានវិវាទៈគូភាគីឯកភាពគ្នាក្នុងការឈប់រស់នៅជាអនីតិសង្វាស

## សំអាងហេតុ

.ដើមចោទបានអះអាងនៅពេលធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនៅពេលធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថាៈ ទាមទារសុំឈប់រស់នៅជាអនីតិសង្វាសជាមួយចុងចម្លើយដោយសំអាងថាការរស់នៅជាមួយគ្នាមិនសូវចុះសម្រុងនឹងគ្នាចេះតែរកាំរកូសនឹងឈ្លោះប្រកែកគ្នាជាញឹកញាប់ ហើយខ្លួនបានបែកលំនៅសង្វាសពីចុងចម្លើយអស់រយៈពេលជិត២ឆ្នាំមកហើយ ទង្វើនេះហើយធ្វើឲ្យខ្លួន

អស់មនោសញ្ចេតនាពីចុងចម្លើយអាចឲ្យតុលាការពិចារណាបាន ឯចុងចម្លើយក៏ឯកភាពតាមការសុំរបស់ដើមចោទដែរ ចំណុចនេះអាចឲ្យតុលាការពិនិត្យនិងសម្រេចបាន ។

.ដើមចោទនិងចុងចម្លើយបានរៀបការតាមប្រពៃណីនៅក្នុងឆ្នាំ២០១៨ តែពុំទាន់បានចុះសំបុត្រអាពាហ៍ពិពាហ៍តាមមាត្រា៩៥៥ នៃក្រមរដ្ឋប្បវេណីឡើយ ដូចនេះគូភាគីរស់នៅជាអនីតិសង្វាសនឹងគ្នាអាចឲ្យតុលាការពិចារណា ។

.ចំពោះអាហារកិច្ចចិញ្ចឹមកូនដែលភាគីចុងចម្លើយសុំទាមទារឲ្យដើមចោទបង់ផ្តាច់ចំនួន៣.០០០ ដុល្លាអាមេរិកនោះ ភាគីដើមចោទអះអាងថាកូននោះមិនមែនជាកូនរបស់ខ្លួនឡើយខ្លួនមិនទទួលស្គាល់ទឡើយ ព្រោះអំឡុងពេលរៀបការជាមួយគ្នាដើមចោទរស់នៅជាប្តីប្រពន្ធជាមួយចុងចម្លើយតែចំនួន២០សប្តាហ៍ប៉ុណ្ណោះ តែពេលដែលខ្លួនជូនចុងចម្លើយទៅពិនិត្យអេកូនដើម្បីមើលផ្ទៃពោះ គឺឃើញថាកូននោះមានអាយុចំនួន២៥សប្តាហ៍០២ថ្ងៃ ចំណែកឯចុងចម្លើយក៏បាននិយាយថាមុនពេលខ្លួនរៀបការជាមួយដើមចោទខ្លួនខឹងឪពុកម្តាយហើយក៏បានផឹកស្រាស្រវឹងហើយមានគេចាប់ខ្លួនដែរ ចំណុចនេះគប្បីតុលាការមិនសម្រេចទាក់ទងនិងការស្នើសុំអាហារកិច្ចរបស់ចុងចម្លើយឡើយ ។

.តាមកិច្ចសន្យាបំបែកអនីតិសង្វាសជាប្តីប្រពន្ធ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០ ១៨ របស់ភាគីទាំងពីរបានបញ្ជាក់ថាគូភាគីបានព្រមព្រៀងគ្នាក្នុងការឈប់រស់នៅជាអនិតិសង្វាសពីគ្នា ដោយគ្មានការបង្ខិតបង្ខំនិងមានការទាមទារអ្វីឡើយ ចំណុចនេះអាចអោយតុលាការពិចារណាបាន ។

.គប្បីឲ្យដើមចោទជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

## សេចក្តីសម្រេចបញ្ចប់

**១**.ឲ្យដើមចោទឈ្មោះ [redacted] ស្មាអេល និងចុងចម្លើយឈ្មោះ [redacted] សើណាស់ ឈប់រស់នៅជាអនីតិសង្វាសនឹងគ្នាចាប់ពីថ្ងៃប្រកាសសាលក្រមតទៅ ។

**២**.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

.................................................................................................................

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៨កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

កំពត,ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

កំពត ថ្ងៃទី ០.៥ ខែ សីហា 2020

ក្រឡាបញ្ជី

[redacted]